មហានគរ FM93.50
វិទ្យុឯករាជ្យ បំរើប្រជាពលរដ្ឋ

ភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ ភ្នំពេញ
ទូរស័ព្ទ : 092 913 111/ 099 999 579
អ៊ីម៉ែល : mhnk.info@yahoo.com
info@fm935kh.org
គេហទំព័រ : www.fm935kh.org

លេខ : 081/08 មហាវគរ

# លិខិតថ្លែងអំណរគុណ

## សូមគោរពជូន

## ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន

ជាបឋម តាងនាមអោយស្ថានីយ៍វិទ្យុមហានគរ FM93.5MHz ខ្ញុំបាទមានកិត្តិយសសូមថ្លែងនូវអំណរគុណចំពោះក្តីមេត្តាករុណាដ៏ខ្ពង់ខ្ពស់ ដែលឯកឧត្តមរដ្ឋមន្ត្រីបានសណ្តោសប្រណីខន្តីអភ័យទោស ក៏ដូចជាបានអនុញ្ញាតអោយស្ថានីយ៍វិទ្យុមហានគរ FM93.5MHz បានបន្តសុពលភាពការផ្សាយរបស់ខ្លួនឡើងវិញ ។

ជាថ្មីម្តងទៀត ខ្ញុំបាទសូមសន្យាជាឧឡារិកចំពោះ ឯកឧត្តមរដ្ឋមន្ត្រី ថាជារាបតទៅនឹងគោរពអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងព័ត៌មាន ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធនានាអោយបានខ្ជាប់ខ្ជួន ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

ខ្ញុំបាទសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាគ្រប់ទិសទាំងប្រាំបី សូមលោកប្រសិទ្ធិពរជ័យសិរីសួស្តី វិបុលសុខគ្រប់ប្រការ ជូនចំពោះឯកឧត្តមរដ្ឋមន្ត្រី អោយជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តមរដ្ឋមន្ត្រី ទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ភ្នំពេញ, ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០៨

នាយកគ្រប់គ្រង

ព្រះរាជាណាចក្រកម្ពុជា
មហានគរ
FM93.5MHz
ជាតិ សាសនា ព្រះមហាក្សត្រ

មង់_ចិត្រា